# ក្រុមមេធាវីការពារក្តី មាស មុត
# MEAS MUTH DEFENCE TEAM
# EQUIPE DE DEFENSE DE MEAS MUTH

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Jul-2014, 08:30
CMS/CFO: Sann Rada

**អាង ឧត្តម និង Michael G. KARNAVAS**
សហមេធាវីការពារក្តីលោក មាស មុត
ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១៤

គោរពជូន៖ លោកចៅក្រម **យូ ប៊ុនឡេង**
លោកចៅក្រម **Mark HARMON**
សហចៅក្រមស៊ើបអង្កេត

កម្មវត្ថុ៖ សំណើសុំព័ត៌មានទាក់ទងនឹងការខ្វែងគំនិតគ្នាកត់ត្រានៅថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ ២០១៣ និង នៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៣

សូមគោរពជូនចំពោះលោកសហចៅក្រមស៊ើបអង្កេត៖

នៅថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០១៤ យើងខ្ញុំបានទទួលសេចក្តីជូនដំណឹងលេខ D82/3 "សេចក្តីជូនដំណឹងទាក់ទងនឹងសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿង និង សុំចូលរួមក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ (D82) និង សុំដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរសំណៅទាំងមូល និង សម្ភារៈឯកសារគាំទ្រ (D82/2)"។ សេចក្តីជូនដំណឹងនេះនិយាយអំពីការខ្វែងគំនិតគ្នាដែលត្រូវបានដាក់នៅថ្ងៃទី ០៧ និង ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៣។

យើងខ្ញុំយល់ថា ការខ្វែងគំនិតគ្នារវាងសហចៅក្រមស៊ើបអង្កេត គឺជាការសម្ងាត់។ ប៉ុន្តែ ឯកសារនេះនឹងជួយយើងខ្ញុំក្នុងការដាក់សំណើសុំការពិចារណាបន្ថែម ដែលស្នើដោយសេចក្តីជូនដំណឹងលេខ D82/3 ប្រសិនបើយើងខ្ញុំអាចទទួលបានព័ត៌មានអំពីចរិតលក្ខណៈគោលនៃការខ្វែងគំនិតគ្នានេះ និង អំពីថាតើការខ្វែងគំនិតគ្នានេះបច្ចុប្បន្នស្ថិតនៅចំពោះមុខអង្គបុរេជំនុំជម្រះ ឬយ៉ាងណានោះ។ យើងខ្ញុំកត់សម្គាល់ឃើញថា គ្រប់ដីកាទាំងអស់ដែលបានចេញកន្លងមក ដែលយើងខ្ញុំបានទទួលពីសហចៅក្រមស៊ើបអង្កេត Harmon និង សេចក្តីប្រកាសព័ត៌មានដែលចេញដោយសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០១៣ បាននិយាយតែអំពីការខ្វែងគំនិតគ្នាដែលបានដាក់នៅថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ ២០១៣ ប៉ុណ្ណោះ។ ដូច្នេះ យើងខ្ញុំមិនបានដឹងថាមានការខ្វែងគំនិតគ្នាបន្ថែមមួយទៀតដែលបានដាក់នៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១៣ នោះឡើយ។

សូមលោកចៅក្រមមេត្តាទទួលយកលិខិតនេះដោយក្តីគោរព។

សហមេធាវីការពារក្ដីលោក មាស មុត

អាង ឧត្តម Michael G. KARNAVAS